អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មាន

## សហចៅក្រមស៊ើបអង្កេត ផ្សព្វផ្សាយឯកសារមួយចំនួនជាសាធារណៈ

នៅថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេត បានប្រកាសថា ខ្លួននឹងផ្សព្វផ្សាយនូវឯកសារមួយចំនួនបន្ថែមទៀតទាក់ទិននឹងកិច្ចស៊ើបសួរដែលកំពុងដំណើរការ ទៅតាមការអនុញ្ញាតដូចមានចែងនៅក្នុងវិធាន ៥៦(២) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និងក្នុងគោលបំណងធ្វើឲ្យកាន់តែប្រសើរឡើងក្នុងការផ្តល់ព័ត៌មានដល់សាធារណជន ដោយគោរពផងដែរដល់ការការពារជីវិតឯកជន និងសច្ចធារណ៍និរទោស ព្រមទាំងធានាដល់ប្រសិទ្ធភាពនៃកិច្ចស៊ើបសួរ។

ចាប់តាំងពីពេលនោះមក ការិយាល័យសហចៅក្រមស៊ើបអង្កេត បានធ្វើការពិនិត្យឯកសារនៃសំណុំរឿងដោយយកចិត្តទុកដាក់ ដើម្បីធ្វើការជ្រើសរើសឯកសារណាដែលអាចផ្សព្វផ្សាយនៅលើគេហទំព័ររបស់ អ.វ.ត.ក។

ហេតុដូចនេះ នៅក្នុងដំណាក់កាលដំបូងនេះ សហចៅក្រមស៊ើបអង្កេត បានសម្រេចផ្សព្វផ្សាយជាសាធារណៈនូវឯកសារទាំងអស់នៃសំណុំរឿងដែលពាក់ព័ន្ធនឹងបញ្ហាសំខាន់មួយដែលចង់ដឹងថាតើ សញ្ញាណសហឧក្រិដ្ឋកម្មរួម (ស្គាល់ច្បាស់ជាអក្សរកាត់ជាភាសាអង់គ្លេស JCE) អាចត្រូវបានយកមកអនុវត្តនៅក្នុងនីតិវិធីដែលកំពុងដំណើរការដែរ ឬទេ។ ឯកសារទាំងនេះ រួមមាន៖

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

- សំណើដំបូងរបស់មេធាវីការពារមួយក្រុម ដែលចង់ឲ្យឃើញមានការមិនអនុវត្តសញ្ញាណនេះ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៨
- ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០០៨
- ដីការបស់សហចៅក្រមស៊ើបអង្កេត ដែលស្នើឲ្យភាគីនានាផ្ដល់ការអត្ថាធិប្បាយទាំងអស់ដែលខ្លួនមាន ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៨
- ដោយយោងដីការបស់សហចៅក្រមស៊ើបអង្កេត សារណានានាដែលដាក់ចូលក្នុងសំណុំរឿងដោយភាគីនានាចុះថ្ងៃទី ២៤ ខែវិច្ឆិកា និងថ្ងៃទី ២៤ ទី៣០ និងទី៣១ ខែធ្នូ ឆ្នាំ ២០០៨

នៅពេលដែលចៅក្រម សម្រេចលើបញ្ហានេះ ប្រាកដណាស់សេចក្ដីសម្រេចនេះ នឹងត្រូវផ្សព្វផ្សាយផងដែរ។

ដីកានានារបស់សហចៅក្រមស៊ើបអង្កេត មាននៅលើគេហទំព័រ៖
http://www.eccc.gov.kh/khmer/court_doc.list.aspx?courtDocCat=ocij_docs

ពាក្យសុំ និងសារណានានារបស់ភាគី មាននៅលើគេហទំព័រ៖

- របស់សហព្រះរាជអាជ្ញា៖
http://www.eccc.gov.kh/khmer/court_doc.list.aspx?courtDocCat=ocp_docs
- របស់មេធាវីការពារក្ដី៖
http://www.eccc.gov.kh/khmer/court_doc.list.aspx?courtDocCat=defence_docs
- របស់ដើមបណ្ដឹងរដ្ឋប្បវេណី៖
http://www.eccc.gov.kh/khmer/court_doc.list.aspx?courtDocCat=cp_docs

ការផ្សព្វផ្សាយជាសាធារណៈនេះ នឹងមានជាបន្តបន្ទាប់ជាទៀងទាត់។ម្យ៉ាងទៀត សហចៅក្រម សូមរំលឹកថា របាយការណ៍តុលាការដែលចុះផ្សាយនៅលើគេហទំព័ររបស់អង្គជំនុំជម្រះមានព័ត៌មានថ្មីៗប្រចាំខែពីសកម្មភាពបច្ចុប្បន្ននៃកិច្ចស៊ើបសួរដែលកំពុងមាន៖
(http://www.eccc.gov.kh/khmer/publications.aspx)

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០០៩

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.